ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរៈបរិស្ថាន

**Climate-Friendly Agribusiness Value Chains Sector Project (CFAVC)**

**ADB Loan No. 3661-CAM (COL), 8346-CAM (EF) and Grant No. 0579 (EF)**

# ឯកសារមេរៀនបណ្តុះបណ្តាល

# ស្តីពី

# ការចុះបញ្ជីគណនេយ្យ

# សម្រាប់សហគមន៍កសិកម្ម

រៀបចំដោយ៖ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម (DACP)

**ឆ្នាំ ២០២០**

# មាតិកា

**១. គណនេយ្យ និងការចុះបញ្ជីគណនេយ្យ** 2
**២. តើហេតុអ្វីបានជាសហគមន៍កសិកម្មត្រូវចុះបញ្ជីគណនេយ្យ?** 2
**៣. ប្រតិបត្តិការអាជីវកម្ម** 2
**៤. ប្រភេទបញ្ជីគណនេយ្យ** 3
ក- គណនេយ្យឯកភាគ 3
ខ- គណនេយ្យទ្វេភាគ 3
**៥. ប្រភេទគណនី:** 4
ក- គណនីទ្រព្យសកម្ម 4
ខ- គណនីបំណុល 4
គ- គណនីដើមទុនរបស់សហគមន៍កសិកម្ម 5
ឃ- គណនីចំណូល 5
ង- គណនីចំណាយ 5
**៦-របាយការណ៍ហិរញ្ញវត្ថុ** 7
**៧. ការគណនាថ្លៃដើមទំនិញ** 9
ជំហានទី១ 9
ជំហានទី២ 9
ជំហានទី៣ 9
**៨. ជំហ៊ានសំខាន់ៗសម្រាប់ធ្វើរបាយការណ៍លទ្ធផល និងរបាយការណ៍តុល្យការ** 11
**ជំហ៊ានទី១**៖ ប្រមូលផ្តុំឯកសារពាក់ព័ន្ធ 11
**ជំហ៊ានទី២** ៖ វិភាគប្រតិបត្តិការ 12
**ជំហ៊ានទី៣**៖ ធ្វើតារាងតុល្យភាពសាកល្បងចុងគ្រា 20

## ១. គណនេយ្យ និងការចុះបញ្ជីគណនេយ្យ

**គណនេយ្យ** គឺជាដំណើរការនៃការកត់ត្រា រាយការណ៍ វិភាគ និងបកស្រាយព័ត៌មានហិរញ្ញវត្ថុរបស់អង្គភាពអាជីវកម្ម ដែលក្នុងនោះរួមមានសហគមន៍កសិកម្មផងដែរ។ មានការយល់ច្រឡំជាទូទៅថា គណនេយ្យ និងការចុះបញ្ជីគណនេយ្យ គឺជាកិច្ចការតែមួយ។ ប៉ុន្តែតាមការពិត ការចុះបញ្ជីគណនេយ្យគ្រាន់តែជាផ្នែកមួយនៃដំណើរការការងាររបស់គណនេយ្យប៉ុណ្ណោះ។

មានន័យថា **ការចុះបញ្ជីគណនេយ្យ** គឺជាការប្រមូល និងកត់ត្រាព័ត៌មានហិរញ្ញវត្ថុទៅក្នុងបញ្ជីគណនេយ្យ ឬទៅក្នុងប្រព័ន្ធកុំព្យូទ័រ រីឯកិច្ចការគណនេយ្យអនុវត្តលើសពីការកត់ត្រា ដោយរួមមានទាំងការរៀបចំរបាយការណ៍ វិភាគ និងបកស្រាយ ដូចមានគូសបញ្ជាក់ក្នុងនិយមន័យខាងលើ។ ដូច្នេះកិច្ចការគណនេយ្យមានលក្ខណៈទូលំទូលាយ និងប្រើប្រាស់ជំនាញខ្លាំងជាងការកត់ត្រាបញ្ជីគណនេយ្យ។

## ២. តើហេតុអ្វីបានជាសហគមន៍កសិកម្មត្រូវចុះបញ្ជីគណនេយ្យ?

គឺមានគោលបំណង៣សំខាន់ៗ៖

១- ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិសហគមន៍អោយបានត្រឹមត្រូវល្អ

២-ដើម្បីគណនាចំណាយ ចំណូល និង ធ្វើរបាយការណ៍ហិរញ្ញវត្ថុរបស់សហគមន៍

៣-ដើម្បីផ្តល់ទំនុកទុកចិត្តដល់សមាជិកសហគមន៍កសិកម្ម និង អ្នកចង់រកស៊ីជាមួយសហគមន៍កសិកម្ម

## ៣. ប្រតិបត្តិការអាជីវកម្ម

**ប្រតិបត្តិការអាជីវកម្ម** គឺជាសកម្មភាពដែលទាក់ទងទៅនឹងការប្រែប្រួលទ្រព្យសកម្ម បំណុល ទុនសមាជិកសហគមន៍ ចំណូល និង ចំណាយ ដែលត្រូវបានគេកត់ត្រាចូលក្នុងបញ្ជីគណនេយ្យ ។ វាគឺជាព្រឹត្តិការណ៍នៃការផ្លាស់ប្តូរទំនិញ សេវា ឬ ប្រាក់ជាដើម។

ឧទាហរណ៍នៃប្រតិបត្តិការអាជីវកម្មរួមមាន ការទិញទំនិញ សម្ភារបរិក្ខារ ការទូទាត់ចំណាយលើសេវាដឹកជញ្ជូន ការបើកប្រាក់ខែជូនបុគ្គលិក ការខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ការដាក់ទុនវិនិយោគរបស់សមាជិក និងការលក់ទំនិញ និងសេវាជាដើម។ ប្រតិបត្តិការអាជីវកម្មត្រូវបានបង្ហាញឲ្យឃើញតាមរយៈបញ្ជីស្នាមរបស់សហគមន៍កសិកម្ម ដូចជាប័ណ្ណសាច់ប្រាក់ចេញ ប័ណ្ណសាច់ប្រាក់ចូល វិក្កយបត្រ និងឯកសារភស្តុតាងដទៃទៀត។ ប្រតិបត្តិការអាជីវកម្មត្រូវបានកត់ត្រា ទុកនៅកន្លែងដោយឡែកៗពីគ្នាក្នុងប្រព័ន្ធគណនេយ្យដែលគេហៅថា**គណនី** ដើម្បីរៀបចំប្រមូលផ្តុំបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

- **គណនី**

គឺជាតារាងមួយលំអិតនៃការប្រែប្រួលជាប្រក្រតីរបស់ខ្ទង់ជំពូកដោយឡែកៗណាមួយនៅលើរបាយការណ៍ ហិរញ្ញវត្ថុក្នុងរយៈពេលកំណត់ជាក់លាក់មួយ ។ គណនីគឺជាការដាក់ឈ្មោះលើសកម្មភាពនិមួយៗនៅក្នុងប្រតិបត្តិការមុខជំនួញ ឬសេវាកម្មនានា។

ខ្លឹមសាររបស់គណនី:

**១_** ត្រូវមានឈ្មោះ

**២_** ខាងឆ្វេងហៅថា ឥណពន្ធ

**៣_** ខាងស្តាំហៅថា ឥណទាន

៤_ សមតុល្យដើមគ្រា ៖ ប្រាក់សល់ពីគ្រាមុន

៥_ ចំនួនកើតមាននៅក្នុងគ្រា ៖ ប្រតិបត្តិការ កើតឡើងក្នុងគ្រា

៦_ សមតុល្យចុងគ្រា ៖ សំណល់ទូទាត់រួចដែលនៅសល់ចុងគ្រា

## ៤. ប្រភេទបញ្ជីគណនេយ្យ

**ក- គណនេយ្យឯកភាគ** ៖ អង្គការ ឬ ស្ថាប័នរដ្ឋ (មានតែចំណូល និង ចំណាយ)

**ខ- គណនេយ្យទ្វេភាគ** ៖ប្រព័ន្ធចុះបញ្ជីគណនេយ្យទ្វេភាគ គឺជាវិធីស្តង់ដារនៃការកត់ត្រារក្សាទុក ដែលជាទូទៅត្រូវបានគេប្រើប្រាស់ក្នុងមុខរបរជាច្រើនដោយអ្នកចុះបញ្ជីនិងគណនេយ្យករសម្រាប់សហគ្រាសទូទៅ ។ វាណែនាំពីគោលគំនិតនៃឥណពន្ធនិងឥណទាន ដែលមានន័យថារាល់ប្រតិបត្តិការ ឬ សកម្មភាពមួយតែងតែមាននៅខាង (ឥណពន្ធ)និងមាននៅខាង(ឥណទាន) ដូច្នេះប្រតិបត្តិការដែលត្រូវបានកត់ត្រា ជះឥទ្ធិពលទៅលើគណនីពីរឬច្រើន ។

សហគមន៍កសិកម្មត្រូវប្រើប្រាស់គណនេយ្យទ្វេភាគពីព្រោះសហគមន៍កសិកម្មគឺជាសហគ្រាសសេដ្ឋកិច្ចដែលធ្វើមុខជំនួញ ដែលទាក់ទងទៅនឹងការចំណាយ ចំណូល និង ចំណេញ ។ គណនេយ្យទ្វេភាគគឺជាគណនេយ្យបង្ហាញថា ប្រតិបត្តិការមួយត្រូវមានគណនីពីរឬលើសនេះកើតឡើង។

រាល់គណនី គឺមានផ្នែកឥណពន្ធនិងឥណទាន។ ឥណពន្ធគឺនៅខាងឆ្វេងរីឯឥណទានគឺនៅខាងស្តាំ។ ព្រោះតែប្រតិបត្តិការរងឥទ្ធិពលពីរ នោះរាល់ឥទ្ធិពលសរុបនៅខាងឆ្វេង គឺតែងតែស្មើនឹងឥទ្ធិពលសរុបនៅខាងស្តាំ ។ ដូច្នេះ ឥណពន្ធគឺស្មើនឹងឥណទាន ។

ពាក្យថា**ឥណពន្ធ**មានន័យថាខាងឆ្វេង និង**ឥណទាន**មានន័យថាខាងស្តាំ។ ក្នុង**ប្រព័ន្ធគណនេយ្យទ្វេភាគ**បានតម្រូវឲ្យកត់ត្រាប្រតិបត្តិការអាជីវកម្មនីមួយៗទៅក្នុងគណនីចំនួនពីរ ឬលើសពីពីរ ដោយគោរពទៅតាមវិធានដូចតទៅ៖

- ឥឡូវនេះគឺជាច្បាប់៖ ការកើនឡើងទ្រព្យសកម្ម អ្នកកត់ត្រានៅខាងឥណពន្ធរបស់គណនីទ្រព្យសកម្ម ការថយចុះទ្រព្យសកម្ម អ្នកកត់ត្រានៅខាងឥណទានរបស់គណនីទ្រព្យសកម្ម ។

វាផ្ទុយពីបំណុលនិងដើមទុន ដែល៖

- ការកើនឡើងគណនីបំណុលឬដើមទុន អ្នកកត់ត្រានៅខាងឥណទាន របស់គណនីបំណុល ឬដើមទុន ការថយចុះគណនីបំណុលឬដើមទុនអ្នកកត់ត្រានៅខាងឥណពន្ធរបស់គណនីបំណុលឬដើមទុន។
- ការកើនឡើងនៃចំណូល ត្រូវកត់ត្រាខាងផ្នែកឥណទានរបស់គណនីចំណូល។ ការថយចុះនៃចំណូល ត្រូវកត់ត្រាខាងផ្នែកឥណពន្ធរបស់គណនីចំណូល។
- ការកើនឡើងនៃចំណាយ ត្រូវកត់ត្រាខាងផ្នែកឥណពន្ធរបស់គណនីចំណាយ។ ការថយ ចុះនៃចំណាយ ត្រូវកត់ត្រាខាងផ្នែកឥណទានរបស់គណនីចំណាយ។

គុណប្រយោជន៍នៃប្រព័ន្ធចុះបញ្ជីគណនេយ្យទ្វេភាគ គឺថាវាមានដំណើរការដើម្បីធានានូវភាពត្រឹមត្រូវនិងពេញលេញក្នុងការកត់ត្រារាល់ប្រតិបត្តិមុខរបរ ។ វាគឺជាប្រភពនៃព័ត៌មានហិរញ្ញវត្ថុដែលអាចទុកចិត្តបាននិងការវាយតម្លៃសុក្រិតចំពោះលក្ខ័ណ្ឌឬសកម្មភាពនៃមុខរបរ ។

ចំណងជើងគណនី

| ឥណពន្ធ (ខាងឆ្វេង) | ឥណទាន (ខាងស្តាំ) |
|---|---|

## ៥. ប្រភេទគណនី:

### ខាងក្រោមជាគំនូសបំព្រួញស្តីពីវិធានកត់ត្រា
### ឥណពន្ធ និងឥណទានដែលត្រូវចងចាំ




ជាទូទៅដើម្បីបានរបាយការណ៍ហិរញ្ញវត្ថុ សហគមន៍កសិកម្មត្រូវស្គាល់គណនីប្រភេទសំខាន់ៗ ដូចតទៅព្រោះវាទាក់ទងនឹងរបាយការណ៍ធំៗ ២ គឺ ៖របាយការណ៍តុល្យការ និងរបាយការណ៍លទ្ធផល។

គណនីប្រភេទសំខាន់ៗមានចំនួន៥ ផ្នែកដូចតទៅ៖

**ក- គណនីទ្រព្យសកម្ម៖** ជាគណនីសម្រាប់កត់ត្រាទុកទ្រព្យសកម្មរបស់សហគមន៍កសិកម្ម។ ទ្រព្យសកម្ម គឺជាវត្ថុ ឬធនធានដែលអាចគិតជាតម្លៃបាន និងជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម។

ទ្រព្យសកម្មរបស់សហគមន៍ ចែកចេញជា២ផ្នែក គឺ ៖

*១-ទ្រព្យសកម្មរយៈពេលខ្លី រួម*មាន ៖

- សាច់ប្រាក់ឬ**បេឡា**របស់សហគមន៍
- ប្រាក់ផ្ញើនៅធនាគារ
- ប្រាក់ឱ្យសមាជិកសហគមន៍ ឬអ្នកខាងក្រៅខ្ចី (ប្រាក់ឱ្យគេខ្ចី)
- ប្រាក់គេជំពាក់ត្រូវទារ (ការប្រាក់ត្រូវទារ សេវាគេបានជួលឃ្លាំង ត្រាក់ទ័រ ម៉ាស៊ីន ឬឧបករណ៍កសិកម្ម គ្រឿងយន្តកសិកម្មផ្សេងៗត្រូវទារ)
- បន្ទុកពិនិត្យមុន(ប្រាក់កក់មុនសម្រាប់ទិញ ឬជួលអ្វីមួយ)
- គណនីអតិថិជន **ឬគណនីត្រូវទទួល**(គេទិញទំនិញសហគមន៍ជំពាក់)
- គណនីទិញទំនិញទ្រព្យក្នុងស្តុក ឬ**ស្តុកទំនិញ**ក្នុងឃ្លាំង

*២-ទ្រព្យសកម្មរយៈពេលវែង* ៖ មាន **ដីធ្លី អគារ ឧបករណ៍ សម្ភារការិយាល័យ តុ ទូ កៅអី កុំព្យូទ័រ ម៉ាស៊ីន គ្រឿងយន្តកសិកម្ម** ។ល។

**ខ- គណនីបំណុល៖** ជាគណនីសម្រាប់កត់ត្រាទុកបំណុលរបស់សហគមន៍កសិកម្ម។ បំណុល គឺជាប្រាក់ដែលសហគមន៍កសិកម្មជំពាក់បុគ្គលដទៃ។ ហេតុដូច្នេះសហគមន៍ត្រូវតែសងគេវិញតាមពេលកំណត់ជាក់

លាក់មួយ ដោយមានការប្រាក់ ឬ គ្មានការប្រាក់ ។ គណនីបំណុលនេះមានបំណុលរយៈពេលខ្លី និង បំណុលរយៈពេលវែង។ គណនីបំណុលរួមមានៈ

- ប្រាក់ខ្ចីពីធនាគារ
- ប្រាក់បញ្ញើសន្សំរបស់សមាជិក **ឬរបស់អ្នកខាងក្រៅ**
- ប្រាក់បញ្ញើសន្សំមានការកំណត់របស់សមាជិក ឬបុគ្គលណាម្នាក់
- គណនីអ្នកផ្គត់ផ្គង់ ឬគណនីត្រូវសង (ទិញទំនិញដែលយកមកលក់ជំពាក់គេ)
- ប្រាក់ជំពាក់គេ (ប្រាក់មិនទាន់បង់ថ្លៃទិញវត្ថុមកប្រើប្រាស់ ការប្រាក់ជំពាក់គេត្រូវបង់ សេវាកម្មនានា ដូចជា អគ្គិសនី ទឹក ទូរស័ព្ទ ជួលដីគេ ជួលឃ្លាំងគេ ។ល។

**គ- គណនីដើមទុនរបស់សហគមន៍កសិកម្ម៖** ជាគណនីសម្រាប់កត់ត្រាទុកដើមទុនរបស់សហគមន៍កសិកម្ម។ វាជាបរិមាណទឹកប្រាក់ឬភាគហ៊ុនដែលសមាជិកបានដាក់ក្នុងសហគមន៍ ដើម្បីអោយសហគមន៍ប្រកបមុខរបរអ្វីមួយ។ សហគមន៍កសិកម្មមិនចាំបាច់សងទុននោះសមាជិកវិញទេនៅពេលរកស៊ីខាត ប៉ុន្តែអាចសងភាគហ៊ុនវិញនៅពេលសមាជិកនោះលាឈប់ពីសហគមន៍កសិកម្ម ។ សហគមន៍កសិកម្មមានទុនជាច្រើនប្រភេទរួមមាន៖

- ប្រាក់ភាគហ៊ុនរបស់សមាជិក
- ប្រាក់សមាជិកភាពរបស់សមាជិក
- ប្រាក់បំរុងទុករបស់សហគមន៍ប្រចាំឆ្នាំ (20%) ជារៀងរាល់ឆ្នាំ
- ប្រាក់បណ្តុះបណ្តាលប្រចាំឆ្នាំ (3%)
- ប្រាក់អំណោយឧបត្ថម្ភរបស់រដ្ឋាភិបាល
- ប្រាក់អំណោយរបស់សប្បុរសជន ឬអង្គការនានា
- ប្រាក់ចំណេញរក្សាទុក
- ប្រាក់ចំណេញមិនទាន់បែងចែក

**ឃ- គណនីចំណូល៖** ជាគណនីសម្រាប់កត់ត្រាទុកចំណូលរបស់សហគមន៍កសិកម្ម។

**<u>ចំណូល</u>** គឺជាលំហូរចូលនៃទ្រព្យសកម្មដែលបានមកពីការលក់ទំនិញ ឬបម្រើសេវាឲ្យទៅអតិថិជន។ ប្រភេទគណនីចំណូលរួមមានៈ

- ចំណូលការប្រាក់ដែលទទួលបានពីប្រាក់បញ្ញើនៅធនាគារ
- ចំណូលការប្រាក់ដែលទទួល បានពីប្រាក់ឲ្យសមាជិកឬអ្នកខាងក្រៅខ្ចី
- ចំណូលពីការលក់ទំនិញ
- ចំណូលពីកំរៃជើងសារ និងពីការផ្តល់សេវាផ្សេងៗ។ល។

**ង- គណនីចំណាយ៖** ជាគណនីសម្រាប់កត់ត្រាទុកចំណាយរបស់សហគមន៍កសិកម្ម។

**<u>ចំណាយ</u>**គឺជាលំហូរចេញនៃទ្រព្យសកម្ម ដែលបណ្តាលមកពីប្រតិបត្តិការអាជីវកម្ម។

ប្រភេទគណនីចំណាយរួមមាន ៖

- ចំណាយការប្រាក់បង់ឲ្យធនាគារពាក់ព័ន្ធកម្ចីពីធនាគារ
- ចំណាយការប្រាក់បង់ឲ្យបុគ្គលដែលសហគមន៍កសិកម្មខ្ចីប្រាក់
- ការប្រាក់បង់ឲ្យសមាជិកដែលដាក់សន្សំក្នុងសហគមន៍
- ចំណាយទិញទំនិញ (ថ្លៃដើមទំនិញ)
- ចំណាយសេវានានាដូចជា ការធ្វើដំណើរ ការលើកដាក់លីសែង ទូរគមនាគមន៍ជាដើម។ល។

## គណនីផ្សេងៗគ្នានៅក្នុងផ្នែកទ្រព្យសកម្ម បំណុល ទុនសហគមន៍ ចំណាយ និង ចំណូល

| ផ្នែក | ឈ្មោះគណនី | ការពន្យល់អំពីខ្លឹមសារ |
|---|---|---|
| ទ្រព្យសកម្ម | បេឡាសាច់ប្រាក់ | ប្រាក់ដែលមាននៅក្នុងដៃ (រូបិយប័ណ្ណ ជាដើម) |
| | គណនីប្រាក់ផ្ញើធនាគារ | គណនីដែលផ្ញើនៅតាមស្ថាប័នហិរញ្ញវត្ថុដូចជាធនាគារជាដើម |
| | ប្រាក់ឱ្យគេខ្ចី | ប្រាក់ឱ្យសមាជិកខ្ចី ឬមិនមែនសមាជិកខ្ចីមានលិខិតសន្យា |
| | គណនីអតិថិជន ឬគណនីត្រូវទារ | ថ្លៃលក់ទំនិញផ្គត់ផ្គង់ តែមិនទាន់បានទទួលប្រាក់(លក់ទំនិញជឿជូនអតិថិជន) |
| | ប្រាក់កក់ទំនិញ | ប្រាក់កក់ទំនិញទុកមុនមិនទាន់បានទទួលទំនិញ |
| | គណនីទិញទំនិញ (ស្តុកទំនិញ) | ទំនិញទិញចូលទុកលក់ (ទ្រព្យក្នុងស្តុក) ឬស្តុកទំនិញសល់ក្នុងឃ្លាំង |
| | ដីធ្លី | ដីដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម |
| | អគារ | អគារដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម |
| | ឧបករណ៍ការិយាល័យ | តុនិងកុំព្យូទ័រជាដើមដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម |
| | សម្ភារៈដឹកជញ្ជូន | សម្ភារៈដឹកជញ្ជូនដែលជាកម្មសិទ្ធិរបស់សហគមន៍កសិកម្ម |
| | សំភារៈផ្សេងៗ | |
| បំណុល | ប្រាក់បញ្ញើមានកាលកំណត់ឬបញ្ញើសន្សំ | ប្រាក់បញ្ញើរបស់សមាជិកជាដើម (បញ្ញើក្រៅពីសមាជិកក៏មានដែរ) |
| | ប្រាក់ខ្ចីធនាគារ | ប្រាក់ដែលសហគមន៍ខ្ចីមកពីធនាគារ |
| | គណនីអ្នកផ្គត់ផ្គង់ ឬគណនីត្រូវសង | ថ្លៃទិញទំនិញផ្គត់ផ្គង់ តែមិនទាន់បានបង់ (ទិញទំនិញជឿ) |
| | ប្រាក់មិនទាន់បង់ឬជំពាក់គេ | បំណុលក្រៅពីថ្លៃទិញជឿនូវទំនិញសម្រាប់លក់ |
| ទុន សហគមន៍ | ប្រាក់ចូលភាគហ៊ុន | បរិមាណទឹកប្រាក់ដែលសមាជិកដាក់ទុនវិនិយោគ |
| | ប្រាក់សមាជិកភាព | ប្រាក់បង់ចូលជាសមាជិក |
| | មូលនិធិបំរុង | ប្រាក់ដែលត្រូវដកពីប្រាក់ចំណេញសុទ្ធ២០%ប្រចាំឆ្នាំ (ដោយច្បាប់) |
| | ទុនបណ្តុះបណ្តាល | ប្រាក់ដែលត្រូវដកពីប្រាក់ចំណេញសុទ្ធ៣%ប្រចាំឆ្នាំ (ដោយច្បាប់) |
| | មូលនិធិស្ម័គ្រចិត្ត | មូលនិធិដែលសហគមន៍ដកសន្សំទុកទិញទ្រព្យអ្វីមួយពង្រីកមុខរបរស.ហ |
| | ប្រាក់ចំណេញមិនទាន់បែងចែក | ប្រាក់ចំណេញសុទ្ធបានពីមុខរបរសហគមន៍មិនទាន់បែងចែក |
| | អំណោយពីសប្បុរសជន និង អង្គការ | ប្រាក់អំណោយពីសប្បុរសជន និងអង្គការនានា |
| | អំណោយពីរាជរដ្ឋាភិបាល | ប្រាក់អំណោយពីរដ្ឋ |
| ចំណាយ | ចំណាយការប្រាក់នៃប្រាក់បញ្ញើ ឬសន្សំ | បរិមាណការប្រាក់ចំណាយ នៃប្រាក់ដែលគេផ្ញើ |
| | ចំណាយការប្រាក់នៃប្រាក់ខ្ចីពីខាងក្រៅ | បរិមាណការប្រាក់ចំណាយ នៃប្រាក់ដែលបានខ្ចីខាងក្រៅ |
| | ចំណាយទិញទំនិញ | ថ្លៃដើមទិញទំនិញសម្រាប់ផ្គត់ផ្គង់ |
| | ចំណាយលើការធ្វើដំណើរ | ថ្លៃធ្វើដំណើរទៅធ្វើការខាងក្រៅនិងថ្លៃធ្វើដំណើរទៅធ្វើការនៅការិយាល័យ |
| | ចំណាយលើទូរគមនាគមន៍ | ថ្លៃទំនាក់ទំនងដូចជាប្រៃសណីយ៍និងទូរស័ព្ទជាដើម |
| | ចំណាយលើកដាក់លីសែង | ថ្លៃចំណាយលើកម្មករ |
| | ចំណាយផ្សេងៗ | ថ្លៃចំណាយផ្សេងទៀត |
| ចំណូល | ចំណូលការប្រាក់នៃប្រាក់ផ្ញើនៅធនាគារ | បរិមាណការប្រាក់បានពីប្រាក់ផ្ញើនៅធនាគារ |
| | ចំណូលការប្រាក់នៃប្រាក់ឱ្យគេខ្ចី | បរិមាណការប្រាក់បានពីប្រាក់ដែលអោយគេខ្ចី |
| | ចំណូលពីកាលក់ទំនិញ | ថ្លៃលក់ទំនិញផ្គត់ផ្គង់ |
| | កម្រៃជើងសារទទួលបាន | បរិមាណកម្រៃជើងដែលទទួលបាន |
| | ចំណូលពីសេវាកម្មផ្សេងៗ | ការផ្តល់សេវាកម្មផ្សេងៗដូចជាជួលត្រាក់ទ័រ ម៉ាស៊ីនកិនស្រូវ គោយន្ត។ល។ |

## ៦-របាយការណ៍ហិរញ្ញវត្ថុ

**របាយការណ៍ហិរញ្ញវត្ថុ**

| **តារាងតុល្យការ** | **របាយការណ៍លទ្ធផល** |
|---|---|
| • ទ្រព្យសកម្ម<br>• បំណុល<br>• ទុន | • ចំណូល<br>• ចំណាយ<br>• (ចំណេញ/ខាត) |

➢ **របាយការណ៍តុល្យការៈ**

បានបង្ហាញនូវគ្រប់ទ្រព្យសកម្ម និងទ្រព្យអកម្ម(បំណុល) និងដើមទុនរបស់សហគមន៍កសិកម្មនៅចុងការិយបរិច្ឆេទ គឺបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់សហគមន៍កសិកម្មក្នុងរយៈពេលជាក់លាក់មួយ។

***របាយការណ៍តុល្យការ*** *គឺជារបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញអំពីដែលបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ (ទ្រព្យ បំណុល និងទុន) របស់សហគមន៍កសិកម្មក្នុងពេលកំណត់មួយ។ តួលេខក្នុងរបាយការណ៍តុល្យការជាតួលេខដែលបូកយោងបន្តពីគ្រាមួយទៅគ្រាមួយ។*

ទំរង់តារាងតុល្យការ

| | |
|---|---|
| ទ្រព្យសកម្ម | បំណុល |
| | ទុនសហគមន៍ |

ឧទាហរណ៍

| | | | |
|---|---|---|---|
| ទ្រព្យសកម្ម | | បំណុល+<br>ទុនសហគមន៍ | |
| សាច់ប្រាក់ | 2 000 000 | ប្រាក់សន្សំរបស់សមាជិក<br>ប្រាក់ភាគហ៊ុន | 500 000<br>1 500 000 |
| សរុបទ្រព្យសកម្ម = | 2 000 000 | សរុបបំណុល + ទុន = | 2 000 000 |

សមីការឬរូបមន្តដែលត្រូវចងចាំក្នុងការគណនា និង ការរៀបចំធ្វើតារាងតុល្យការ

ទ្រព្យសកម្មសរុប = បំណុលសរុប + ទុនសហគមន៍កសិកម្ម

**ឬ** ទ្រព្យសកម្មសរុប – បំណុលសរុប = ទុនសរុបរបស់សហគមន៍កសិកម្ម

**ទ្រព្យសកម្ម** ដែលមាននៅក្នុងរបាយការណ៍តុល្យការវា**មានសមតុល្យ** ខាង **ឥណពន្ធ**

ឧទាហរណ៍ គណនីសាច់ប្រាក់ (ទ្រព្យសកម្ម)

| (ឥណពន្ធ) | (ឥណទាន) |
|---|---|
| **សមតុល្យដើមគ្រា** | |
| + ចំនួនកើតមាននៅក្នុងគ្រា | – ចំនួនកើតឡើងក្នុងគ្រា |
| ចំនួនសរុបខាងឥណពន្ធ | ចំនួនសរុបខាងឥណទាន |
| **សមតុល្យចុងគ្រា** | |

សមតុល្យចុងគ្រា(ទ្រព្យសកម្ម)=សមតុល្យដើមគ្រា+សរុបចំនួនកើតមានក្នុងគ្រាខាងឥណពន្ធ-សរុបចំនួនកើតមានក្នុងគ្រាខាងឥណទាន

**បំណុល ឬទុន** ដែលមាននៅក្នុងរបាយការណ៍តុល្យការវា **មានសមតុល្យ** ខាង **ឥណទាន**

ឧទាហរណ៍:

គណនីភាគហ៊ុន (បំណុលឬទុន)

| (ឥណពន្ធ) | (ឥណទាន) |
|---|---|
| | **សមតុល្យដើមគ្រា** |
| – ចំនួនកើតមាននៅក្នុងគ្រា | + ចំនួនកើតឡើងក្នុងគ្រា |
| ចំនួនសរុបខាងឥណពន្ធ | ចំនួនសរុបខាងឥណទាន |
| | **សមតុល្យចុងគ្រា** |

សមតុល្យចុងគ្រា(ទុនឬបំណុល)=សមតុល្យដើមគ្រា+ចំនួនកើតមានក្នុងគ្រាខាងឥណទាន-ចំនួនកើតមានក្នុងគ្រាខាងឥណពន្ធ

- **របាយការណ៍លទ្ធផល:**

បានរាយការណ៍ពីចំណូល ចំណាយ និងបង្ហាញពីប្រាក់ចំណេញឬខាត ដែលបង្កើតឡើងដោយសហគមន៍កសិកម្មសម្រាប់អំឡុងពេលនីមួយៗ។ ប្រាក់ចំណេញក្នុងមួយអំឡុងពេលត្រូវបានគណនាដោយយក៖ **ចំណូល** ដក **ចំណាយ** ។

**ចំណូល** ពីការលក់ទំនិញនិងចំណូលផ្សេងៗទៀត ត្រូវបានរាយការណ៍នៅផ្នែក **ឥណទាន ក្នុង** របាយការណ៍លទ្ធផល ។

**ចំណាយ** ត្រូវបានចុះនៅ **ឥណពន្ធ** ក្នុងរបាយការណ៍លទ្ធផល ។

***របាយការណ៍លទ្ធផល*** *គឺជារបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញអំពីលទ្ធផលនៃកិច្ចប្រតិបត្តិការអាជីវកម្មរបស់សហគមន៍កសិកម្ម ដែលក្នុងនោះបង្ហាញចំណូល និងចំណាយ ដែលកើតមានក្នុងគ្រា និងចំណេញឬខាតក្នុងពេលកំណត់មួយ។*

## ៧. ការគណនាថ្លៃដើមទំនិញ

អាចត្រូវបានគណនាតាមរូបមន្តដូចតទៅ៖

**ថ្លៃដើមនៃទំនិញដែលបានលក់ចេញ = ស្តុកទំនិញដើមគ្រា + ថ្លៃដើមទំនិញដែលបានទិញចូលសម្រាប់លក់ក្នុងគ្រា - ស្តុកទំនិញចុងគ្រា**

នៅក្នុងរូបមន្តនេះ ជាដំបូងយើងចាំបាច់ត្រូវកំណត់រកថ្លៃដើមទំនិញក្នុងមួយឯកតាសម្រាប់ គណនារកថ្លៃដើមស្តុកទំនិញដែលនៅសល់ចុងគ្រា មុននឹងគណនារកថ្លៃដើមទំនិញដែលបានលក់ចេញ។ យើងអាចប្រើប្រាស់វិធីសាស្ត្រជាទូទៅ៤សម្រាប់កំណត់រកគឺ (១) វិធីសាស្ត្រថ្លៃដើមជាក់ស្តែងឬមធ្យមភាគប្រែប្រួល (២) វិធីសាស្ត្រមធ្យមទម្ងន់ (៣) វិធីសាស្ត្រចូលមុនចេញមុន និង (៤) វិធីសាស្ត្រចូលក្រោយចេញមុន។ ក្នុងឯកសារនេះ យើងផ្តោតតែទៅលើវិធីសាស្ត្រមធ្យមទម្ងន់ និងវិធីសាស្ត្រចូលមុនចេញមុនប៉ុណ្ណោះ ។

### ១-វិធីសាស្ត្រមធ្យមទម្ងន់៖

គឺជាវិធីសាស្ត្រថ្លៃក្នុង១ឯកតានៃស្តុកនៅចុងគ្រា (ចុងខែ) ដោយគណនាថ្លៃក្នុង១ឯកតាមធ្យមនៃស្តុកនីមួយក្នុងកំឡុងពេលមួយជាក់លាក់ (១ខែឬ១ឆ្នាំ) ដោយយកតម្លៃសរុបនៃទ្រព្យដែលទិញចូលក្នុងស្តុកទាំងអស់ទៅចែកនឹងចំនួនក្នុងស្តុកដែលបានទិញសរុបក្នុងកំឡុងពេលនោះ។

**ឧទាហរណ៍ក្នុងខែមករា៖**

- ថ្ងៃទី01 ទិញជីចំនួន50បាវ ក្នុងតម្លៃ 150.000 រៀល/បាវ
- ថ្ងៃទី02 លក់ជីចំនួន40បាវ ថ្លៃ 200.000 រៀល/បាវ
- ថ្ងៃទី10 ទិញជីចំនួន30បាវ ក្នុងតម្លៃ 180.000 រៀល/បាវ
- ថ្ងៃទី18 លក់ជីចំនួន70បាវ ថ្លៃ 220.000 រៀល/បាវ
- ថ្ងៃទី20 ទិញជីចំនួន60បាវ ក្នុងតម្លៃ 200.000 រៀល/បាវ
- ថ្ងៃទី31 បានលក់ជីចំនួន10បាវ ថ្លៃ 230.000 រៀល/បាវ។

ផ្អែកលើប្រតិបត្តិការទិញលក់នេះ ថ្លៃដើមជីក្នុងមួយឯកតាដែលត្រូវកំណត់រក អាចត្រូវបានគណនាដោយអនុវត្តតាមវិធីសាស្ត្រមធ្យមទម្ងន់ដូចតទៅ៖

**ជំហានទី១៖** បូកបរិមាណជីដើមគ្រានិងបរិមាណជីដែលបានទិញចូលទាំងអស់ ដើម្បីកំណត់រកបរិមាណជីសរុបដែលមានសម្រាប់លក់។ អាស្រ័យដោយហេតុថា យើងមានបំណងរៀបចំរបាយការណ៍ប្រចាំខែធ្នូ ដូច្នេះពាក្យថាដើមគ្រា គឺសំដៅទៅដល់ដើមខែធ្នូ រីឯពាក្យចុងគ្រា ដែលយើងនឹងយើងខាងក្រោមគឺសំដៅទៅដល់ចុងខែធ្នូ។

**ជំហានទី២៖** បូកថ្លៃដើមជីសរុបដែលមាននៅដើមគ្រា និងថ្លៃដើមជីសរុបដែលបានទិញចូលទាំងអស់ ដើម្បីកំណត់រកថ្លៃដើមជីសរុបដែលមានសម្រាប់លក់។

**ជំហានទី៣៖** ចែកថ្លៃដើមជីសរុបដែលមានសម្រាប់លក់ នឹងបរិមាណជីសរុបដែលមានសម្រាប់លក់ ដើម្បីកំណត់រកថ្លៃដើមជីជាមធ្យមសម្រាប់គណនារកថ្លៃដើមជីដែលនៅសល់ចុងគ្រា។

ផ្អែកលើជំហានទាំង៣ យើងអាចគណនាដូចខាងក្រោម៖

ជីដើមគ្រា 0 រៀល

ជីទិញចូល 50បាវ x 150.000 រៀល = 7.500.000 រៀល

ជីទិញចូល 30បាវ x 180.000 រៀល = 5.400.000 រៀល

ជីទិញចូល 60បាវ x 200.000 រៀល = 12.000.000 រៀល

ជីសម្រាប់លក់ 140បាវ 24.900.000 រៀល

ថ្លៃដើមជីក្នុងមួយឯកតា

= 24.900.000 រៀល/140បាវ ដូចនេះ = 177.857 រៀល/បាវ

ថ្លៃដើមជីនៅសល់ចុងគ្រា

= 20បាវ x 177.857 រៀល/បាវ ដូចនេះថ្លៃដើមចុងគ្រាសរុប= 3.557.140 រៀល

ថ្លៃដើមជីដែលបានលក់ចេញ

= 24.900.000រៀល - 3.557.140 រៀល

= 21.342.860 រៀល

## ២-វិធីសាស្ត្រចូលមុនចេញមុន ៖

វិធីសាស្ត្រចូលមុនចេញមុន គឺជាវិធីសាស្ត្រគណនាថ្លៃទំនិញក្នុង១ឯកតានៃទំនិញក្នុងស្តុកចុងគ្រា ឬចុងខែ ដោយបញ្ចេញទំនិញដែលទិញចូលមុនគេបង្អស់តាមលំដាប់លំដោយហើយសន្មតថាទំនិញដែលទិញចូលក្រោយគេបង្អស់ជាទំនិញក្នុងស្តុកចុងគ្រា។

លំហូរនេះមានលក្ខណៈងាយបើប្រៀបធៀបវិធីសាស្ត្រដទៃ ភាគច្រើនត្រូវរួមជាមួយលំហូរទំនិញជាក់ស្តែង។

### ឧទាហរណ៍ក្នុងខែមករា៖

សៀវភៅធំគណនីស្តុកទំនិញ

| កាលបរិច្ឆេទ | | កំណត់សំគាល់ | ទិញចូល | | | លក់ចេញ | | | សមតុល្យ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ថ្លៃឯកតា | សរុប | បរិមាណ | ថ្លៃឯកតា | សរុប | បរិមាណ | ថ្លៃឯកតា | សរុប |
| ខែ1 | 01 | ស្តុកសល់ផ្ទេរពីខែមុន | 100 | @300 | 30.000 | | | | 100 | @ 300 | 30.000 |
| | 02 | ទិញចូល | 50 | @360 | 18.000 | | | | 100<br>50 | @ 300<br>@ 360 | 30.000<br>18.000 |
| | 03 | ផ្គត់ផ្គង់ចេញ | | | | 60 | @300 | 18.000 | 40<br>50 | @ 300<br>@ 360 | 12.000<br>18.000 |
| | 15 | ទិញចូល | 150 | @400 | 60.000 | | | | 40<br>50<br>150 | @ 300<br>@ 360<br>@ 400 | 12.000<br>18.000<br>60.000 |
| | 17 | ផ្គត់ផ្គង់ចេញ | | | | 20 | @300 | 6.000 | 20<br>50<br>150 | @ 300<br>@ 360<br>@ 400 | 6.000<br>18.000<br>60.000 |
| | 25 | ផ្គត់ផ្គង់ចេញ | | | | 20<br>50<br>30 | @300<br>@360<br>@400 | 6.000<br>18.000<br>12.000 | 120 | @400 | 48.000 |
| | 30 | សរុបខែ1 | 300 | | 108.000 | 180<br>120 | <br>@400 | 60.000<br>48.000 | | | |
| | | ស្តុកផ្ទេរទៅខែក្រោយ | 300 | | 108.000 | 300 | | 108.000 | | | |
| ខែ2 | 1 | ស្តុកសល់ផ្ទេរពីខែមុន | 120 | @400 | 48.000 | | | | 120 | @400 | 48.000 |

## ៨. ជំហានសំខាន់ៗសម្រាប់ធ្វើរបាយការណ៍លទ្ធផល និងរបាយការណ៍តុល្យការ

ជំហានទី១ ៖ ប្រមូលផ្តុំឯកសារពាក់ព័ន្ធ

ជំហានទី២ ៖ វិភាគប្រតិបត្តិការ ក្នុងករណីមានប្រតិបត្តិការកើតឡើងក្នុងគ្រា ដើម្បីរកគណនីដែលពាក់ព័ន្ធនឹងប្រតិបត្តិការនោះ ដោយវិភាគលេខនាកំណត់ខាងឥណពន្ធ និងឥណទាន រួចស្រង់ចុះចូលទិន្នានុប្បវត្តិទូទៅតាមលំដាប់ ជាមួយគ្នានេះដែរ ស្រង់ទិន្នន័យដែលបានចុះក្នុងសៀវភៅទិនានុប្បវត្តិទូទៅចូលគណនីសៀវភៅធំ។ ចុងខែនិមួយៗត្រូវបិទគណនី រកសមតុល្យចុងគ្រា គណនីសៀវភៅធំ ដោយទូទាត់តាមរូបមន្ត ។

ជំហានទី៣ ៖ ធ្វើតារាងតុល្យភាពសាកល្បងចុងគ្រា

ជំហានទី៤ ៖ ត្រួតពិនិត្យមើលចំណុចមួយចំនួនដែលត្រូវរៀបចំកែតម្រូវដើម្បីបិទបញ្ជី និងធ្វើតារាងតុល្យភាពកែតម្រូវ

ជំហានទី៥ ៖ ធ្វើរបាយការណ៍លទ្ធផលនិង របាយការណ៍តុល្យការ

### ជំហានទី១ ៖ ប្រមូលផ្តុំឯកសារពាក់ព័ន្ធ

សហគមន៍កសិកម្មត្រូវប្រមូលផ្តុំឯកសារពាក់ព័ន្ធ ដោយត្រូវរៀបចំបញ្ជីមួយ ឬតារាងតុល្យភាពមួយដោយបញ្ចូលចំណូល ចំណាយ ទ្រព្យសកម្ម បំណុល និងទុនទាំងអស់របស់សហគមន៍កសិកម្ម ។ ឯកសារដែលត្រូវប្រមូលរួមមានៈ

១ - បញ្ជីបេឡាប្រចាំខែ បញ្ជីវិលស់ទ្រព្យសកម្មរយៈពេលវែង បញ្ជីតាមដានបំណុលរបស់សមាជិកសហគមន៍កសិកម្ម វិក័យបត្រលក់ជឿឱ្យអតិថិជន ទំនិញសល់ក្នុងស្តុកចុងឆ្នាំ សមតុល្យ ឬអ្វីដែលសល់ពីការទូទាត់ខែមុន ក្លាយជាដើមគ្រាសម្រាប់ខែថ្មី។

### ឧទាហរណ៍តារាងតុល្យភាពសាកល្បងចុងគ្រា

ត្រឹមថ្ងៃទី 30 ខែ វិច្ឆិកា ឆ្នាំ 2019

| ឈ្មោះគណនី | ចុងខែវិច្ឆិកា | |
|---|---|---|
| **ទ្រព្យសកម្ម** | **ឥណពន្ធ** | **ឥណទាន** |
| សាច់ប្រាក់ | 5,200,000 | |
| ប្រាក់ផ្ញើធនាគារ | 300,000 | |
| ប្រាក់ឱ្យគេខ្ចី | 50,000 | |
| គណនីអតិថិជនឬគណនីត្រូវទទួល | 100,000 | |
| ទ្រព្យសកម្មរយៈពេលវែង(ត្រាក់ទ័រ) | 2,200,000 | |
| **បំណុល** | | |
| ប្រាក់ខ្ចីធនាគារ | | 3,500,000 |
| ប្រាក់ជំពាក់គេ | | 50,000 |
| **ទុន** | | |
| ប្រាក់ភាគហ៊ុនសរុប | | 3,230,000 |
| **ចំណូលសរុប** | | 1,150,000 |
| **ចំណាយសរុប** | 80,000 | |
| **សរុប** | **7,930,000** | **7,930,000** |

ឧទាហរណ៍ក្នុងករណីមានសកម្មភាព ឬប្រតិបត្តិការកើតឡើងក្នុងអាជីវកម្មនៅខែថ្មី (ខែធ្នូ) ឆ្នាំ2019

**ប្រតិបត្តិការទី១** ៖ នៅថ្ងៃទី 02 ធ្នូ បានទទួលប្រាក់ភាគហ៊ុនដែលសមាជិកបង់ចំនួន 200 000 រៀល ជាសាច់ប្រាក់ ។

**ប្រតិបត្តិការទី២**: នៅថ្ងៃទី 02 ធ្នូ បានទទួលសាច់ប្រាក់ដល់ដៃដែលសមាជិកយកមកសន្សំក្នុងសហគមន៍ចំនួន 400 000 រៀល។

**ប្រតិបត្តិការទី៣**:នៅថ្ងៃទី02ធ្នូ បានផ្តល់បេឡាសាច់ប្រាក់ឱ្យពូសំដែលជាសមាជិកខ្ចីចំនួន 500000រៀល

**ប្រតិបត្តិការទី៤**: ថ្ងៃទី 03 ធ្នូ សហគមន៍បានទិញជីអ៊ុយរ៉េ ចំនួន100បាវ ដោយតម្លៃ1បាវ150 000 រៀល ហើយឱ្យសាច់ប្រាក់ដល់ដៃ5 000 000៛ សល់ប៉ុន្មានជំពាក់នឹងសងក្រោយប្រមូលផល។

**ប្រតិបត្តិការទី៥** :ថ្ងៃទី 05 ធ្នូ សហគមន៍បានលក់ជីអ៊ុយរ៉េទៅឱ្យសមាជិកចំនួនសរុបចំនួន 80បាវ ដោយទទួលបានជាសាច់ប្រាក់ដល់ដៃ បានក្នុង1បាវ តម្លៃ 165 000 រៀល ។

**ប្រតិបត្តិការទី៦** : នៅថ្ងៃទី 06 ធ្នូ បានទិញស្រូវពីសមាជិកចំនួន 2.000គីឡូក្រាម បង់ជាសាច់ប្រាក់ដល់ដៃឱ្យសមាជិកតម្លៃ1 គីឡូ 900 រៀល។

**ប្រតិបត្តិការទី៧**: នៅថ្ងៃទី 15 ធ្នូ បានលក់ស្រូវឱ្យរោងម៉ាស៊ីនកិនស្រូវចំនួន 1 800គីឡូក្រាម បានក្នុងតម្លៃ ១គីឡូ 1 100 រៀល ដោយទទួលបានសាច់ប្រាក់ដល់ដៃ។

**ប្រតិបត្តិការទី៨**: នៅថ្ងៃទី 15 ធ្នូ បានជួលត្រាក់ទ័រឱ្យសមាជិកចំនួន 1ថ្ងៃ បានកម្រៃ 200 000រៀល។

**ប្រតិបត្តិការទី៩**: នៅថ្ងៃទី16 ធ្នូ បានទិញកុំព្យូទ័រ1គ្រឿងក្នុងតម្លៃ800 000៛ហើយនឹងបង់នៅចុងខែមករា

**ប្រតិបត្តិការទី១០**:ថ្ងៃទី 30 ធ្នូ បានចំណាយការប្រាក់ជាសាច់ប្រាក់នៃប្រាក់បញ្ញើសន្សំសមាជិកចំនួន 40000 រៀល

**ប្រតិបត្តិការទី១១**: នៅថ្ងៃទី 30 ធ្នូ បានបង់ការប្រាក់នៃប្រាក់កម្ចីធនាគារចំនួន420 000 រៀល

**ប្រតិបត្តិការទី១២** : នៅថ្ងៃទី 30 ធ្នូ បានទទួលការប្រាក់ជាសាច់ប្រាក់នៃប្រាក់ឱ្យគេខ្ចីចំនួន600រៀល

**ប្រតិបត្តិការទី១៣** : នៅថ្ងៃទី 31 ធ្នូ បានទទួលការប្រាក់ជាសាច់ប្រាក់នៃប្រាក់ផ្ញើធនាគារចំនួន7 500៛

ពីពេលនោះមករហូត ពុំមានប្រតិបត្តិការអ្វីផ្សេងទៀតទេ។

## ជំហានទី២ ៖វិភាគប្រតិបត្តិការ

វិភាគប្រតិបត្តិការដើម្បីរកគណនីដែលពាក់ព័ន្ធនឹងប្រតិបត្តិការនោះ ដោយវិភាគកំណត់ ឈ្មោះគណនី ខាងឥណពន្ធ និងឥណទាន ។

បន្ទាប់មកស្រង់ចុះចូលទិនានុប្បវត្តិទូទៅតាមលំដាប់ ជាមួយគ្នានេះដែរស្រង់ទិន្នន័យដែលបានចុះក្នុងទិនានុប្បវត្តិទូទៅចូលក្នុងគណនីសៀវភៅធំ។

តាមឧទាហរណ៍ខាងលើយើងបានលទ្ធផលដូចខាងក្រោម ៖

***សៀវភៅទិនានុប្បវត្តិទូទៅ***

រាល់ប្រតិបត្តិការអាជីវកម្មទាំងអស់ ចាំបាច់ត្រូវកត់ត្រាចូលក្នុងសៀវភៅ**ទិនានុប្បវត្តិទូទៅ** ដោយគោរពតាមវិធានឥណពន្ធ និងឥណទានខាងលើ។

សៀវភៅទិនានុប្បវត្តិទូទៅ គឺជាសៀវភៅដែលសម្រាប់កត់ត្រាប្រតិបត្តិការអាជីវកម្មដែលកើតឡើងប្រចាំថ្ងៃទាំងអស់។ វាមានកូឡោនសំខាន់ៗចំនួន៤គឺ កូឡោនកាលបរិច្ឆេទ កូឡោនឈ្មោះគណនីនិងបរិយាយ កូឡោនឥណពន្ធ និងកូឡោនឥណទាន។ ការកត់ត្រាចូលក្នុងសៀវភៅទិនានុប្បវត្តិទូទៅ ត្រូវអនុវត្តតាមនីតិវិធីដូចតទៅៈ

(១)- កត់ត្រាកាលបរិច្ឆេទនៃប្រតិបត្តិការអាជីវកម្មក្នុងកូឡោនកាលបរិច្ឆេទ (សូមមើលសៀវភៅទិនានុប្បវត្តិទូទៅខាងក្រោម)។

(២)-កត់ត្រាឈ្មោះគណនីដែលត្រូវចុះបញ្ជីខាងឥណពន្ធ និងគណនីដែលត្រូវចុះបញ្ជីខាងឥណទានព្រមជាមួយនឹងការកត់ត្រាបរិយាយត្រួសៗ នៅពីខាងក្រោមចូលទៅក្នុងកូឡោនឈ្មោះគណនីនិងបរិយាយ (លេខ ថ្ងៃខែ វិក័យប័ត្រ និងឯកសារយោងផ្សេងៗ។ល។)។

(៣)-កត់ត្រាតួលេខឥណពន្ធនៅក្នុងកូឡោនឥណពន្ធ ក្នុងជួរជាមួយគ្នានឹងគណនីដែលត្រូវចុះបញ្ជីខាងឥណពន្ធ

(៤)-កត់ត្រាតួលេខឥណទាននៅក្នុងកូឡោនឥណទាន ក្នុងជួរជាមួយគ្នានឹងគណនីដែលត្រូវចុះបញ្ជីខាងឥណទាន។

## គំរូទិនានុប្បវត្តិទូទៅ

ទំព័រទី១

| កាលបរិច្ឆេទ | | ឈ្មោះគណនី និងបរិយាយ | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|
| (១) | | (២) | (៣) | (៤) |
| ខែ | ថ្ងៃទី | | | |
| ធ្នូ | 02 | សាច់ប្រាក់ | 200.000 | |
| | | ប្រាក់ចូលហ៊ុន<br>(សមាជិកបង់ភាគហ៊ុន) | | 200.000 |

### គំរូគណនីសៀវភៅធំ

គណនីៈសាច់ប្រាក់ ត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | ***5,200,000*** | | ***5,200,000*** |
| ធ្នូ | 2 | (សមាជិកបង់ភាគហ៊ុន) | | 200,000 | | 5,400,000 |

### គំរូគណនីសៀវភៅធំ

គណនីៈប្រាក់ចូលហ៊ុន ត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | | ***3,230,000*** | ***3,230,000*** |
| ធ្នូ | 2 | (សមាជិកបង់ភាគហ៊ុន) | | | 200,000 | 3,430,000 |

# សៀវភៅទិនានុប្បវត្តិទូទៅប្រចាំខែ ធ្នូ ២០១៩

| កាលបរិច្ឆេទ | | ឈ្មោះគណនីនិងបរិយាយ | ឥណពន្ធ | ឥណទាន |
|---|---|---|---|---|
| ខែ | ថ្ងៃទី | | | |
| ធ្នូ | 02 | សាច់ប្រាក់ | 200,000 | |
| | | ភាគហ៊ុន | | 200,000 |
| | | (សមាជិកបង់ភាគហ៊ុន) | | |
| | 02 | សាច់ប្រាក់ | 400,000 | |
| | | ប្រាក់បញ្ញើសន្សំ | | 400,000 |
| | | (សមាជិកដាក់ប្រាក់បញ្ញើសន្សំ) | | |
| | 02 | ប្រាក់ឲ្យខ្ចី | 500,000 | |
| | | សាច់ប្រាក់ | | 500,000 |
| | | (សមាជិកខ្ចីប្រាក់ឈ្មោះពូសំ) | | |
| | 03 | ទិញដី (ស្តុកដី) | 15,000,000 | |
| | | សាច់ប្រាក់ | | 5,000,000 |
| | | អ្នកផ្គត់ផ្គង់ | | 10,000,000 |
| | | (ទិញដីអ៊ុយរ៉េ100បាវឱ្យប្រាក់ខ្លះជំពាក់ខ្លះ) | | |
| ធ្នូ | 05 | សាច់ប្រាក់ | 13,200,000 | |
| | | ចំណូល | | 13,200,000 |
| | | (ចំណូលពីលក់ដីអ៊ុយរ៉េ៨០បាវឱ្យសមាជិក) | | |
| | 06 | ទិញស្រូវ (ស្តុកស្រូវ) | 1,800,000 | |
| | | សាច់ប្រាក់ | | 1,800,000 |
| | | (ទិញស្រូវពីសមាជិក2000គីឡូ) | | |
| | 15 | សាច់ប្រាក់ | 1,980,000 | |
| | | ចំណូល | | 1,980,000 |
| | | (ចំណូលពីលក់ស្រូវឱ្យរោងម៉ាស៊ីន-1800Kg) | | |
| | 15 | សាច់ប្រាក់ | 200,000 | |
| | | ចំណូលសេវាជួលត្រាក់ទ័រ | | 200,000 |
| | | (ចំណូលសេវាជួលត្រាក់ទ័រឱ្យសមាជិក1 ថ្ងៃ) | | |
| ធ្នូ | 16 | ទ្រព្យសកម្មរយៈពេលវែង | 800,000 | |
| | | ប្រាក់ជំពាក់គេ | | 800,000 |
| | | (ទិញកុំព្យូទ័រ១គ្រ.ជំពាក់គេសងចុងខែមករា) | | |
| | 30 | ចំណាយ | 40,000 | |
| | | សាច់ប្រាក់ | | 40,000 |
| | | (ចំណាយការប្រាក់បញ្ញើសន្សំ) | | |
| | 30 | ចំណាយ | 420,000 | |
| | | សាច់ប្រាក់ | | 420,000 |
| | | (ចំណាយការប្រាក់នៃប្រាក់ខ្ចីធនាគារ) | | |
| | 30 | សាច់ប្រាក់ | 600 | |
| | | ចំណូល | | 600 |
| | | (ចំណូលការប្រាក់នៃប្រាក់ឱ្យគេខ្ចី) | | |
| | 31 | សាច់ប្រាក់ | 7,500 | |
| | | ចំណូល | | 7,500 |
| | | (ចំណូលការប្រាក់នៃប្រាក់ផ្ញើធនាគារ) | | |
| | | | 34,548,100 | 34,548,100 |

***គណនីសៀវភៅធំ***

គឺជាសៀវភៅដែលតាមដាននិងកត់ត្រារាល់ប្រតិបត្តិការរបស់គណនី១ៗដែលកើតឡើងពីប្រតិបត្តិការ និងមានសមតុល្យក្នុងពេលកំណត់មួយ (ចំលងចេញពីទិនានុប្បវត្តិ)។

- ក្នុងឈ្មោះគណនីមួយមានគណនីសៀវភៅធំមួយសំរាប់កត់ត្រាមួយមុខៗ ទៅតាមប្រតិបត្តិការប្រចាំថ្ងៃដូចឧទាហរណ៍ខាងក្រោម។ សូមបញ្ជាក់ថាប្រសិនបើមានឈ្មោះគណនីដូចគ្នាកើតឡើងដដែលៗ ប្រើតែគណនីសៀវភៅធំជាមួយគ្នា ចុះជាមួយគ្នារហូតដល់កាលកំណត់បិទការិយបរិច្ឆេទ។

*ឧទាហរណ៍ដូចគណនីសាច់ប្រាក់ខាងក្រោម៖*

- រកសមតុល្យចុងគ្រាខែធ្នូ គឺទូទាត់ចាប់ពីពេលផ្តើមប្រតិបត្តិការដើមខែរហូតដល់ចុងខែ ដោយយោងសមតុល្យដើមគ្រារបស់ខែធ្នូ (ចុងគ្រាខែវិច្ឆិកា) ដោយត្រូវគណនាតាមរូបមន្តដូចមានរៀបរាប់ពីសមតុល្យគណនីទាំង៥ ខាងលើ។

## គណនីសៀវភៅធំ

គណនី ....សាច់ប្រាក់............ ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | *5,200,000* | | *5,200,000* |
| ធ្នូ | 2 | (សមាជិកបង់ភាគហ៊ុន) | | 200,000 | | 5,400,000 |
| | 2 | (សមាជិកដាក់ប្រាក់បញ្ញើសន្សំ) | | 400,000 | | 5,800,000 |
| | 2 | (សមាជិកខ្ចីប្រាក់ឈ្មោះពូសំ) | | | 500,000 | 5,300,000 |
| | 3 | (ទិញជីអ៊ុយរ៉េ100បាវឱ្យប្រាក់ខ្លះជំពាក់ខ្លះ) | | | 5,000,000 | 300,000 |
| | 5 | (ចំណូលពីលក់ជីអ៊ុយរ៉េ៨០បាវឱ្យសមាជិក) | | 13,200,000 | | 13,500,000 |
| | 6 | (ទិញស្រូវពីសមាជិក2000kg) | | | 1,800,000 | 11,700,000 |
| | 15 | (ចំណូលពីលក់ស្រូវឱ្យរោងម៉ាស៊ីន-1800Kg) | | 1,980,000 | | 13,680,000 |
| | 15 | (ចំណូលសេវាជួលត្រាក់ទ័រឱ្យសមាជិក1 ថ្ងៃ) | | 200,000 | | 13,880,000 |
| | 30 | (ចំណាយការប្រាក់បញ្ញើសន្សំ) | | | 40,000 | 13,840,000 |
| | 30 | (ចំណាយការប្រាក់ខ្ចីធនាគារ) | | | 420,000 | 13,420,000 |
| | 30 | (ចំណូលការប្រាក់នៃប្រាក់ឱ្យគេខ្ចី) | | 600 | | 13,420,600 |
| | 31 | (ចំណូលការប្រាក់នៃប្រាក់ផ្ញើធនាគារ) | | 7,500 | | 13,428,100 |
| | | **សរុប** | | 15,988,100 | 7,760,000 | 13,428,100 |

ចុងខែនិមួយៗត្រូវបិទគណនី **រកសមតុល្យចុងគ្រា** គណនីសៀវភៅធំ ដោយទូទាត់តាមរូបមន្តខាងលើ។

# គណនីសៀវភៅធំ

គណនី ..ប្រាក់ភាគហ៊ុន.... ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិផ្ទេរទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | | ***3,230,000*** | ***3,230,000*** |
| ធ្នូ | 2 | (សមាជិកបង់ភាគហ៊ុន) | | | 200,000 | 3,430,000 |
| | | **សរុប** | | - | 200,000 | 3,430,000 |

# គណនីសៀវភៅធំ

គណនី ... បញ្ញើសន្សំសមាជិក ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិផ្ទេរទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | | ***0*** | - |
| ធ្នូ | 02 | (សមាជិកដាក់ប្រាក់បញ្ញើសន្សំ) | | | 400,000 | 400,000 |
| | | **សរុប** | | - | 400,000 | 400,000 |

# គណនីសៀវភៅធំ

គណនី: ប្រាក់ឱ្យគេខ្ចី ត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិផ្ទេរទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | ***50,000*** | | ***50,000*** |
| ធ្នូ | 02 | (សមាជិកខ្ចីប្រាក់ឈ្មោះពូសំ) | | 500,000 | | 550,000 |
| | | **សរុប** | | 500,000 | - | 550,000 |

# គណនីសៀវភៅធំ

គណនី: ទិញជី(ស្តុកជី) ត្រឹមថ្ងៃទី ................. ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិផ្ទេរទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | | | |
| ធ្នូ | 3 | (ទិញជីអុយរ៉េ100បាវ ឱ្យរាក់ខ្ចីផងពាក់ខ្ចី) | | 15,000,000 | | |
| | | **សរុប** | | 15,000,000 | - | 15,000,000 |

# គណនីសៀវភៅធំ

គណនី ... អ្នកផ្គត់ផ្គង់ ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងពិពណ៌នាប្រតិបត្តិការ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | | ***0*** | - |
| ធ្នូ | 03 | (ទិញជីអ៊ុយរ៉េ100បាវឱ្យប្រាក់ខ្លះជំពាក់ខ្លះ) | | | 10,000,000 | 10,000,000 |
| | | **សរុប** | | | 10,000,000 | 10,000,000 |

# គណនីសៀវភៅធំ

គណនី ...ចំណូល..... ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងពិពណ៌នាប្រតិបត្តិការ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | | ***1,150,000*** | ***1,150,000*** |
| ធ្នូ | 5 | (ចំណូលពីលក់ជីអ៊ុយរ៉េ៨០បាវឱ្យសមាជិក) | | | 13,200,000 | 14,350,000 |
| | 15 | (ចំណូលពីលក់ស្រូវឱ្យរោងម៉ាស៊ីន-1800Kg) | | | 1,980,000 | 16,330,000 |
| | 15 | (ជួលត្រាក់ទ័រឱ្យសមាជិក1 ថ្ងៃ) | | | 200,000 | 16,530,000 |
| | 30 | (ចំណូលការប្រាក់នៃប្រាក់ឱ្យគេខ្ចី) | | | 600 | 16,530,600 |
| | 31 | (ចំណូលការប្រាក់នៃប្រាក់ផ្ញើធនាគារ) | | | 7,500 | 16,538,100 |
| | | **សរុប** | | | 15,388,100 | 16,538,100 |

# គណនីសៀវភៅធំ

គណនី: ទិញស្រូវ(ស្តុកស្រូវ)............. ត្រឹមថ្ងៃទី ........ ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងពិពណ៌នាប្រតិបត្តិការ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | - | | |
| ធ្នូ | 6 | (ទិញស្រូវពីសមាជិក2000kg) | | 1,800,000 | | |
| | | **សរុប** | | 1,800,000 | - | 1,800,000 |

# គណនីសៀវភៅធំ

គណនី: ទ្រព្យសកម្មរយៈពេលវែង ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងពិពណ៌នាប្រតិបត្តិការ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | ***2,200,000*** | | ***2,200,000*** |
| ធ្នូ | 16 | (ទិញកុំព្យូទ័រ១គ្រ.ជំពាក់គេសងចុងខែមករា) | | 800,000 | | 3,000,000 |
| | | **សរុប** | | 800,000 | - | 3,000,000 |

## គណនីសៀវភៅធំ

គណនី ...ប្រាក់ជំពាក់គេ..... ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | | ***50,000*** | ***50,000*** |
| ធ្នូ | 16 | (ទិញកុំព្យូទ័រ១គ្រ.ជំពាក់គេសងចុងខែមករា) | | | 800,000 | 850,000 |
| | | **សរុប** | | | 800,000 | 850,000 |

## គណនីសៀវភៅធំ

គណនី ...ចំណាយ..... ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | ***80,000*** | | ***80,000*** |
| ធ្នូ | 30 | ចំណាយ យកប្រាក់ន៍ប្រាក់សន្សំ | | 40,000 | | 120,000 |
| | 30 | (ចំណាយ យកប្រាក់ឱ្យធនាគារ) | | 420,000 | | 540,000 |
| | | **សរុប** | | 460,000 | | 540,000 |

## គណនីសៀវភៅធំ

គណនី: អតិថិជន ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | ***100,000*** | | ***100,000*** |
| | | **សរុប** | | 100,000 | - | 100,000 |

## គណនីសៀវភៅធំ

គណនី: ប្រាក់ផ្ញើធនាគារ ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | ***300,000*** | | ***300,000*** |
| | | **សរុប** | | 300,000 | | 300,000 |

## គណនីសៀវភៅធំ

គណនី ...ប្រាក់ខ្ចីពីធនាគារ ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | | ***3,500,000*** | ***3,500,000*** |
| | | **សរុប** | | | 3,500,000 | 3,500,000 |

# សៀវភៅទិនានុប្បវត្តិទូទៅប្រចាំខែធ្នូ ២០១៩

| បិទស្តុកដើម្បីគណនារកថ្លៃដើមទំនិញដែលបានលក់ចេញ | | | | |
|---|---|---|---|---|
| ធ្នូ | 31 | ចំណាយ | 12,000,000 | |
| | | ទិញដី (ស្តុកដី) | | 12,000,000 |
| | | (ចំណាយថ្លៃដើមដីដែលបានលក់ចេញ៨០បារ) | | |
| | 31 | ចំណាយ | 1,620,000 | |
| | | ទិញស្រូវ (ស្តុកស្រូវ) | | 1,620,000 |
| | | (ចំណាយថ្លៃដើមស្រូវដែលបានលក់ចេញ១៨០០គ.ក) | | |

**បញ្ជាក់៖** *ទិនានុប្បវត្តិនេះអាចចុះបន្តពីទិន្នានុប្បវត្តិដែលបានវិភាគប្រតិបត្តិការក្នុងគ្រាបាន*

## គណនីសៀវភៅធំ

គណនី ...ចំណាយ..... ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | ***80,000*** | | ***80,000*** |
| ធ្នូ | 30 | ចំណាយការប្រាក់នៃប្រាក់សន្សំ | | 40,000 | | 120,000 |
| | 30 | (ចំណាយការប្រាក់ខ្ចីធនាគារ) | | 420,000 | | 540,000 |
| | 31 | (ចំណាយថ្លៃដើមដីអ៊ុយជដែលបានលក់៨០បារ) | | 12,000,000 | | 12,540,000 |
| | 31 | (ចំណាយថ្លៃដើមស្រូវបានលក់1800Kg) | | 1,620,000 | | 14,160,000 |
| | | **សរុប** | | 14,080,000 | | 14,160,000 |

## គណនីសៀវភៅធំ

គណនី ...ទិញស្រូវ(ស្តុកស្រូវ) ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | | | |
| ធ្នូ | 3 | (ទិញដីអ៊ុយជ100បារឱ្យប្រាក់ខ្លះជំពាក់ខ្លះ) | | 15,000,000 | | |
| | 31 | (ចំណាយថ្លៃដើមដីអ៊ុយជដែលបានលក់៨០បារ) | | | 12,000,000 | |
| | | **សរុប** | | 15,000,000 | 12,000,000 | 3,000,000 |

## គណនីសៀវភៅធំ

គណនី ...ទិញស្រូវ(ស្តុកស្រូវ) ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| កាលបរិច្ឆេទ | | យោងទិនានុប្បវត្តិទូទៅ | យោង | ឥណពន្ធ | ឥណទាន | សមតុល្យ |
|---|---|---|---|---|---|---|
| ខែ | ថ្ងៃទី | | | | | |
| វិច្ឆិកា | 30 | ***សមតុល្យដើមគ្រា*** | | - | | |
| ធ្នូ | 6 | (ទិញស្រូវពីសមាជិក2000kg) | | 1,800,000 | | |
| | 31 | (ចំណាយថ្លៃដើមស្រូវបានលក់1800Kg) | | | 1,620,000 | |
| | | **សរុប** | | 1,800,000 | 1,620,000 | 180,000 |

*តារាងតុល្យភាពសាកល្បងចុងគ្រា*

តារាងតុល្យភាពសាកល្បងចុងគ្រាគឺជាតារាងដែលជួយដល់ការបញ្ជាក់ថា តើការចុះបញ្ជីលើវិធាន ឥណពន្ធ ឥណទាន ត្រូវឬខុស បញ្ជាក់ថាតើភាពស្មើគ្នាក្នុងការចុះគ្រប់បណ្តាខ្ទង់គណនីទាំងអស់ ត្រូវឬខុស ជាពិសេសវាជាស្ពានមួយដែលយើងអាចងាយស្រួលក្នុងការតម្លើងជារបាយការណ៍លទ្ធផល និង តារាងរបាយការណ៍ឬតារាងតុល្យការ។

## ជំហានទី៣៖ ធ្វើតារាងតុល្យភាពសាកល្បងចុងគ្រា

ស្រង់ទិន្នន័យសមតុល្យសៀវភៅធំរបស់គណនីទាំងអស់ចូលក្នុងតារាងតុល្យភាពសាកល្បងចុងគ្រា។ ខាងក្រោមជាគំរូតារាងតុល្យភាពសាកល្បងចុងគ្រា (ចុងខែធ្នូ)។

## តារាងតុល្យភាពសាកល្បងចុងគ្រា

ត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2019

| ឈ្មោះគណនី | ចុងខែធ្នូ | |
|---|---|---|
| **ទ្រព្យសកម្ម** | **ឥណពន្ធ** | **ឥណទាន** |
| សាច់ប្រាក់ | 13,428,100 | |
| ប្រាក់ផ្ញើធនាគារ | 300,000 | |
| ប្រាក់ឱ្យគេខ្ចី | 550,000 | |
| គណនីអតិថិជនឬគណនីត្រូវទទួល | 100,000 | |
| ស្តុកដី | 3,000,000 | |
| ស្តុកស្រូវ | 180,000 | |
| ទ្រព្យសកម្មរយៈពេលវែង(ត្រាក់ទ័រ+កុំព្យូទ័រ | 3,000,000 | |
| **បំណុល** | | |
| ប្រាក់ខ្ចីធនាគារ | | 3,500,000 |
| ប្រាក់ជំពាក់គេ | | 850,000 |
| អ្នកផ្គត់ផ្គង់ | | 10,000,000 |
| ប្រាក់បញ្ញើសន្សំសមាជិក | | 400,000 |
| **ទុន** | | |
| ប្រាក់ភាគហ៊ុនសរុប | | 3,430,000 |
| **ចំណូលសរុប** | | 16,538,100 |
| **ចំណាយសរុប** | 14,160,000 | |
| **សរុប** | **34,718,100** | **34,718,100** |

តារាងនេះធ្វើជារៀងរាល់ខែ មួយខែម្តង និងជាយោងសម្រាប់ទូទាត់នៅខែបន្តទៀត ។